គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃពុធ ទី ៩ ខែមីនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

ខុមហ្វ្រែល មានកិត្តិយសសូមចេញផ្សាយរបាយការណ៍ ឆ្នាំ២០១០ ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា។ សូមរកមើលឯកសារដែលបានភ្ជាប់មកជាមួយ ឬគេហទំព័រ ខុមហ្វ្រែល។

របាយការណ៍កាលពីឆ្នាំមុន ស្តីពី កំណែទម្រង់ប្រជាធិបតេយ្យ ខុមហ្វ្រែល បានពិនិត្យមើលទៅលើស្ថានភាពនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងប្រជាធិបតេយ្យ និងការបោះឆ្នោត សេរីភាពសំខាន់ៗ អភិបាលកិច្ចប្រជាធិបតេយ្យ ហើយក៏បានពិពណ៌នានូវសកម្មភាពជាច្រើនឈុត ដឹកនាំដោយរដ្ឋាភិបាល និងគណបក្សកាន់អំណាច ដែលបានធ្វើឱ្យចុះថយនូវមុខងារដ៏សំខាន់នៃប្រជាធិបតេយ្យ។

លោក **គល់ បញ្ញា នាយកប្រតិបត្តិនៃគណៈកម្មាធិការ ខុមហ្វ្រែល** បានមានប្រសាសន៍ថា «មានកិច្ចខិតខំប្រឹងប្រែងខ្លះដែលអាចចូលរួមចំណែកឱ្យមានការផ្លាស់ប្តូរតិចតួចនៃការចុះឈ្មោះអ្នកបោះឆ្នោត ការលើកកម្ពស់អំណាចស្ត្រីក្នុងវិស័យនយោបាយ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ខណៈដែលកម្ពុជា ត្រូវការការផ្លាស់ប្តូរដ៏ប្រាកដប្រជាជាច្រើនទៀត ដើម្បីធានាភាពត្រឹមត្រូវនៃការបោះឆ្នោត សេរីភាពបញ្ចេញមតិ ពង្រីកលទ្ធភាពនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងចាត់វិធានការណ៍ជាបន្ទាន់ដើម្បីជួសជុលឡើងវិញនូវលំហរប្រជាធិបតេយ្យ និងកម្រិតនៃទីលានប្រកួតប្រជែងសម្រាប់អ្នកប្រយុទ្ធដើម្បីប្រជាធិបតេយ្យទាំងអស់។

ការបំពេញមុខងាររបស់រដ្ឋាភិបាលតាមគោលនយោបាយបានធ្លាក់ចុះបើតាមការរំពឹងទុករបស់ពលរដ្ឋ។ ក្នុងឆ្នាំ២០១០ អ្នកចូលរួមក្នុងវេទិការបស់ខុមហ្វ្រែលប្រមាណ ៦២ ភាគរយ យល់ថា ការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃគោលនយោបាយបំពេញបានតិចតួច ឬបានល្មម។ ការធ្វើឱ្យប្រសើរឡើងក្នុងស្ថាប័នប្រជាធិបតេយ្យ និងកំណែទម្រង់អភិបាលកិច្ចមានសន្ទុះយឺត។

របាយការណ៍នេះ ផ្តោតលើការស្រាវជ្រាវរបស់ខុមហ្វ្រែល លទ្ធផល និងអនុសាសន៍សម្រាប់កំណែទម្រង់ការបោះឆ្នោត ការវិភាគមួយនៃសេរីភាពមូលដ្ឋានទាំងបីរបស់រដ្ឋ និងលំហរប្រជាធិបតេយ្យ ក្តីបារម្ភអំពីអភិបាលកិច្ចប្រជាធិបតេយ្យនៅកម្ពុជា និងទស្សនៈវិស័យថាមពលអន្តរជាតិ។ ផ្នែកស្តីពីកិច្ចពិភាក្សាកំណែទម្រង់ការបោះឆ្នោត អនុសាសន៍ចំបងៗជាច្រើនត្រូវបានប្រមែប្រមូលពីភាគីពាក់ពន្ធ័

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ដទៃទៀតដើម្បីលើកស្ទួយការបោះឆ្នោតដោយត្រឹមត្រូវ និងតាមដានកិច្ចខំប្រឹងប្រែងដើម្បីសម្រេចបាន នូវសិទ្ធិបោះឆ្នោតជាសកល។ បន្ថែមពីនេះ ផ្នែកផ្សេងទៀត បានពិនិត្យទិដ្ឋភាពវិជ្ជមាន និងភាពប្រឈមមួយចំនួនចំពោះការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ផ្នែកស្តីពី សេរីភាព និងលំហរប្រជាធិបតេយ្យ បានធ្វើបច្ចុប្បន្នកម្មលើស្ថានភាព និងករណីសំខាន់ៗ ដែលប៉ះពាល់ដល់ដំណើរការប្រជាធិបតេយ្យ។ ផ្នែកស្តីពី អភិបាលកិច្ចប្រជាធិបតេយ្យ ផ្តល់នូវការរកឃើញសំខាន់ៗ ពីការឃ្លាំមើលរដ្ឋាភិបាល និងឃ្លាំមើលសភា ការវិភាគទៅលើអង្គភាពប្រឆាំងអំពើពុករលួយ និងពិភាក្សាពីតួនាទីនៃមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធក្នុងសៃវៀននយោបាយ។ ផ្នែកចុងក្រោយ ពិនិត្យលើថាមពលអន្តរជាតិ និងឥទ្ធិពលរបស់ពួកគេនៅក្នុងនយោបាយកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង ៖

លោក **គល់ បញ្ញា** (នាយកប្រតិបត្តិ អង្គការខុមហ្វ្រែល)

ទូរស័ព្ទ ៖ (៨៥៥)-១២-៩៤២-០១៧

**<u>បេសកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។